# សម្ពោធបើកឱ្យប្រើប្រាស់គម្រោងទឹកស្អាត បន្ទប់អនាម័យសម្រាប់បម្រើការព្យាបាល



*លោករដ្ឋមន្ត្រី ម៉ម ប៊ុនហេង ថ្លែងក្នុងពិធី និងអ្នកគ្រូពេទ្យ ព្រមទាំងប្រជាពលរដ្ឋដែលចូលរួម (រូបថត ចំរើន)*

**ខេត្តកំពង់ស្ពឺ ៖** នៅមន្ទីរពេទ្យបង្អែកខេត្ត កាលពីព្រឹកថ្ងៃទី២៩ មិថុនា ពិធីសម្ពោធបើកឱ្យប្រើប្រាស់គម្រោងទឹកស្អាត បន្ទប់អានាម័យ និងមណ្ឌលសុខភាពក្រោមអធិបតីភាពលោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ព្រមទាំងមានការចូលរួមពីលោកម៉ែន សំបូរ អភិបាលរងខេត្ត លោកអោ វ៉ាន់ថេន ប្រធានមន្ទីរសុខាភិបាលខេត្ត និងមន្ត្រីរាជការ បុគ្គលិកមន្ទីរពេទ្យ ប្រជាពលរដ្ឋ និងសិស្សានុសិស្សប្រមាណជាង៣០០នាក់ ។

លោកប្រធានមន្ទីរសុខាភិបាលខេត្តបានអានរបាយការណ៍ថា មន្ទីរសុខាភិបាល ក៏ដូចជាមន្ទីរពេទ្យខេត្តសម្រេចបានលទ្ធផលល្អ លើការពិនិត្យអ្នកជំងឺ ពិនិត្យផ្ទៃពោះ ជំងឺត្រូវវះកាត់ស្បូន ជំងឺតេតាណូស ជំងឺគ្រុនចាញ់ ត្រូវបានកាត់បន្ថយខ្លាំងរហូតមកពេលនេះ ។ សេវាបម្រើវិស័យព្យាបាលអ្នកជំងឺបានល្អ ព្រមទាំងទទួលបានគម្រោងសាងសង់ជាបន្តបន្ទាប់ពីអង្គការ UNICEF អង្គការក្រៅរដ្ឋាភិបាល និងពេលនេះមានអង្គការលៀន អេដស៍ (LIEN AID) និងអង្គការជាដៃគូ BORDA បានផ្តល់គម្រោងសាងសង់អគារ ប្រព័ន្ធទឹកស្អាត ។ មុននេះអង្គការ LIEN AID បានផ្តល់ថវិកាឱ្យដៃគូ BORDA ជាអ្នកសាងសង់លើគម្រោងចំណាយប្រាក់ចំនួន២៤៩.៤៥៥ដុល្លារ សហរដ្ឋអាមេរិក ។ នេះជាស្នាដៃថ្មីមួយដែលមន្ទីរពេទ្យខេត្តសម្រេចបានដោយអង្គការខាងលើធ្វើការអភិវឌ្ឍ ។

តំណាងឱ្យអង្គការលៀន អេដស៍ ឡើងថ្លែងថា អង្គការលៀន អេដស៍ជាអង្គការធ្លាប់ផ្តល់ និងឧបត្ថម្ភ ប្រាក់ជំនួយលើគម្រោងសាងសង់ដល់មន្ទីរពេទ្យជាច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា ។ ឱកាសនេះមន្ទីរពេទ្យខេត្តកំពង់ស្ពឺ ដែលមានអង្គការ BORDA ជាដៃគូ បានសាងសង់អគារបន្ទប់អនាម័យ ទឹកស្អាតដែលខេត្តកំពង់ស្ពឺទទួលបាន២១កន្លែងរួមទាំងមណ្ឌលសុខភាពតាមបណ្តាស្រុកផង ដោយត្រូវចំណាយប្រាក់សរុបចំនួនជាង២៤ម៉ឺនដុល្លារ ។

លោកម៉ែន សំបូរ អភិបាលរងខេត្តបានថ្លែងអំណរគុណដល់អង្គការលៀន អេដស៍ និងអង្គការដៃគូ BORDA ដែលសម្រេចបានអគារព្យាបាលក៏ដូចជាអគារទឹកស្អាត បង្គន់អនាម័យ សេវាកម្មបម្រើដល់អ្នកជំងឺប្រជាពលរដ្ឋក្នុងខេត្ត ទទួលបាននូវភាពសះស្បើយផងដែរ ក្រៅពីការព្យាបាលដោយបង្ការថ្នាំ រួមទាំងសេវាអនាម័យ ទឹកស្អាត កន្លែងស្អាតនោះ ។

លោកបានថ្លែងអំណរគុណដល់លោកវេជ្ជបណ្ឌិតម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ដែលតែងតែជួយឧបត្ថម្ភផ្ទាល់ដល់មន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ ដើម្បីដាស់តឿនមន្ត្រីសុខាភិបាលឱ្យយកចិត្តទុកដាក់ខ្ពស់ក្នុងការព្យាបាល ដោយពុំប្រកាន់និន្នាការនយោបាយ ឬយកលុយកាក់ជាធំនោះទេ។

លោកវេជ្ជបណ្ឌិតម៉ម ប៊ុនហេង បានអំពាវនាវដល់អង្គការក្នុង និងក្រៅប្រទេសដែលពាក់ព័ន្ធឱ្យជួយផ្តល់សេវាផ្នែកសុខភាពដល់ប្រជាពលរដ្ឋកម្ពុជា ពិសេសប្រជាជននៅខេត្តកំពង់ស្ពឺ ដែលតែងកើតជំងឺគ្រុនចាញ់ ជំងឺតេតាណូស ជាពិសេសជំងឺផ្តាសាយបក្សីដែលពុំទាន់ផុតរលត់នៅឡើយ ៕

***ចំរើន***